ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន

# ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

វិច្ឆិកា ២០២៣ - កុម្ភៈ ២០២៤ ភាគ២ ● ភ្នំពេញ



## ការចាប់ផ្តើមធ្វើប្រព្រឹត្តកម្មទឹកកខ្វក់នៅរាជធានីភ្នំពេញ

### ការធ្វើឲ្យប្រសើរឡើងនូវបញ្ហាអនាម័យតាមរយៈការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់



ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ជើងឯក

ដើម្បីសម្រេចបាននូវកំណើនគុណភាពប្រកបដោយនិរន្តភាពតាមរយៈការកាត់បន្ថយវិសមភាព និងការការពារបរិស្ថានផងនោះ ចៃកាបានចូលរួមក្នុងការគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ និងប្រព័ន្ធប្រឡាយលូនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៨ ដោយធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ។ សមិទ្ធផលដ៏គួរឲ្យកត់សម្គាល់មួយគឺ ការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ដំបូងគេនៅរាជធានីភ្នំពេញ កាលពីខែវិច្ឆិកា ឆ្នាំ ២០២៣។

ស្ថានីយនេះត្រូវ បានសាងសង់ឡើងតាមរយៈគម្រោងហិរញ្ញប្បទានឥតសំណងជប៉ុន “ សម្រាប់ការអភិវឌ្ឍប្រព័ន្ធបង្ហូរទឹកនៅរាជធានីភ្នំពេញ “ ដែលមានទឹកប្រាក់ ២,៧៧២លានយ៉េន។ ស្ថានីយនេះបំពាក់ដោយប្រព័ន្ធទំនើបឈ្មោះថា Pre-Trickling (PTF) ដើម្បីធ្វើប្រព្រឹត្តកម្មទឹកកខ្វក់មុននឹងបញ្ចេញ ចូលទៅក្នុងទន្លេ ដែលមានសមត្ថភាពប្រព្រឹត្តកម្ម ៥០០០ ម៉ែត្រគូបក្នុងមួយថ្ងៃជាគម្រោងសាកល្បង។ គម្រោងនេះដែរ បានគាំទ្រ ការកសាងសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋាន ដើម្បីបំពាក់បំប៉នចំណេះដឹង និងជំនាញចាំបាច់ដើម្បីគ្រប់គ្រង និងរក្សាស្ថានីយដែលទើបសាងសងថ្មីនេះ។ ប្រតិបត្តិការប្រកបដោយចីរភាពរបស់ស្ថានីយនេះ តម្រូវឲ្យមានកិច្ចការមួយចំនួនដែលត្រូវអនុវត្ត ដូចជា វិធានការសុវត្ថិភាព ប្រតិបត្តិការសមរម្យ និងការថែទាំ និងការត្រួតពិនិត្យ ។ល។ កង្វះខាតណាមួយក្នុងចំណោម កង្វះខាតទាំងនេះ អាចនាំឲ្យមានការធ្លាក់ចុះនៃអនាម័យ។ កិច្ចសហការជាមួយរដ្ឋាភិបាលមូលដ្ឋានជប៉ុន របស់ទីក្រុង Kita-kyushu ក៏ត្រូវបានផ្តល់ជូនផងដែរសម្រាប់ការ បណ្តុះបណ្តាលជាបន្តបន្ទាប់លើការថែទាំ និងត្រួតពិនិត្យប្រព័ន្ធបង្ហូរទឹក។ ការថែទាំប្រព័ន្ធទឹកកខ្វក់ត្រឹមត្រូវ គឺមានសារៈសំខាន់ក្នុងការកាត់បន្ថយកត្តាដែល បង្កឲ្យមានការស្ទះប្រព័ន្ធលូ និងបង្ហូរទឹក។ កិច្ចខិតខំ ប្រឹងប្រែងទាំងនេះគូសបញ្ជាក់ពីការខិតខំរបស់ចៃកា ក្នុងការបង្កើតអនាគតប្រកបដោយសចីរភាពសម្រាប់កម្ពុជាតាមរយៈការដោះស្រាយបញ្ហាសម្រាម និងប្រព័ន្ធលូបង្ហូរទឹក ចៃកាបាន និងកំពុងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋទាំងមូល៕●

ផ្នែកកសិកម្ម ទឹកស្អាត និងបរិស្ថាន

ទំព័រ ទី២ ទី៣ & ទី៤

**ព័ត៌មានអំពីគម្រោង**

ផលជះពីគម្រោងចៃកាលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈក្នុងប្រទេសកម្ពុជា



សកម្មភាពប្រឡងបញ្ចប់ការសិក្សាជាក់ស្តែងសម្រាប់មុខវិជ្ជាខ្សែភ្លើងនៅ NTTI

និស្សិតអាហារូបករណ៍ចៃកាបានសិក្សាក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ ១៩



កម្មវិធីទទួលសញ្ញាប័ត្រនៅសាកលវិទ្យាល័យ Ritsumeikan Asia Pacific

គម្រោងធ្វើឲ្យប្រសើរឡើងផ្លូវជាតិលេខ៥



ពិធីសម្ពោធផ្លូវជាតិលេខ៥

# ផលជះពីគម្រោងចៃកាលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងប្រទេសកម្ពុជា

វាំងនននៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា សម្រាប់រយៈពេលជាងពីរសវត្សរ៍កន្លងមកសេដ្ឋកិច្ចកម្ពុជាកើនជាមធ្យមប្រមាណ ៧,៣ភាគរយក្នុងមួយឆ្នាំ នៅមុនការរីករាលដាលនៃជំងឺកូវីត១៩ ប្រទេសកម្ពុជាទទួលបាន ភាពរីកចម្រើនឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យម កម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់(ប្រទេសភិវឌ្ឍ) ក្នុងឆ្នាំ២០៥០។ ការកំណត់អំពីតម្រូវការសម្រាប់ អភិវឌ្ឍន៍ប្រកបដោយ ចីរភាពតាមរយៈការទាក់ទាញវិនិយោគផ្ទាល់ ពីក្រៅប្រទេស ពង្រឹងការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈជាគន្លឹះយ៉ាងសំខាន់ដែលមាន ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ការចូលរួមយ៉ាងសំខាន់ ពីចៃកាក្នុង វិស័យ អ.ប.វ ដែលមានជាអាទិ៍ក្នុងគម្រោងការពង្រឹងគុណភាព អ.ប.វ ដើម្បីឆ្លើយតបនឹងតម្រូវការឧស្សាហកម្ម នៅកម្ពុជា (២០១៥-២០២១) ។ ដោយមានការសហការយ៉ាងជិតស្និទ្ធ ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិទ្យាស្ថាន អ.ប.វ សាកល្បងគម្រោងទទួលបានសមិទ្ធិ ផលគោលសំខាន់ៗជាច្រើន។ ដូចជាការផលិតនូវកញ្ចប់ បណ្តុះបណ្តាល ស្តង់ដាកម្រិតសញ្ញាបត្រជាន់ខ្ពស់ ផ្នែកអគ្គិសនីដែលបានអនុមត់ដាក់ឲ្យប្រើប្រាស់ដោយក្រុមប្រឹក្សាបណ្តុះបណ្តាលជាតិកាលពីខែកញ្ញា ឆ្នាំ២០២១ ដែលជាសមិទ្ធផលមួយគួរឲ្យកត់សម្គាល់ និងសមិទ្ធិផលដ៏ទៃជាច្រើនទៀតផងដែរ។



សកម្មភាពប្រឡងបញ្ចប់ការសិក្សាជាក់ស្តែងសម្រាប់មុខវិជ្ជាខ្សែភ្លើងនៅNTTI

ដោយបន្តនូវការប្តេជ្ញាក្នុងការគាំទ្រវិស័យ អ.ប.វ ចៃកាបានបញ្ជូនទីប្រឹក្សាអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងវិស័យឧស្សាហកម្មមកបម្រើការងារនៅក្នុងក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចាប់ពីឆ្នាំ២០២១មក។

ទីប្រឹក្សា មានគោលបំណងបង្កើតនូវយន្តការពង្រឹងគុណភាពវិស័យ អ.ប.វ លើជំនាញអគ្គិសនី ដោយជួយពិនិត្យ និងកែតម្រូវឡើងវិញនូវកម្មវិធី សិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញអគ្គិសនីនៅ វិទ្យាស្ថាន អ.ប.វ គោលដៅដោយសហការជាមួយវិស័យឧស្សាហម្ម។ កន្លងមក ទីប្រឹក្សាបានធ្វើ និងអនុវាត្តសម្មភាពជាច្រើនរួមមានវគ្គបណ្តុះបណ្តាលដល់គ្រូបច្ចេកទេសរបស់វិទ្យាស្ថាន អ.ប.វ សាកល្បងរយៈពេលខ្លីនៅប្រទេសជប៉ុន និងការបង្កើតប្រព័ន្ធភាពជាដៃគូរសាកល្បង ដោយសហការជាមួយយក្រុមហ៊ុនសមាគមជំនួញ របស់ជប៉ុនក្នុងប្រទេសកម្ពុជា។ វគ្គបណ្តុះបណ្តាល នោះបានផ្តល់នូវឱកាសយ៉ាងមានតម្លៃសម្រាប់សិក្ខាកាម ដើម្បីបង្កើតនូវជំនាញ អនុវត្តក្នុងការថែទាំម៉ាស៊ីន និងដំណើរ ការបណ្តាញអគ្គិសនី PLC ជាមួយរោងចក្រផ្ទាល់ ក្នុងគោលបំណងចូលរួមការ បង្រៀន និងការផលិតកម្មវិធីសិក្សានៅវិទ្យាស្ថានអ.ប.វ។ ប្រព័ន្ធភាពជាដៃគូរសាកល្បងបានរឹតចំណងទំនាក់ទំនងរវាងវិទ្យាស្ថាន និង វិស័យឧស្សាហកម្មកាន់តែរឹងមាំ៕●

ផ្នែកអភិវឌ្ឍន៍សង្គម និងអភិបាលកិច្ច

# បញ្ហាប្រឈមកំឡុងពេលកូវីដ១៩របស់និស្សិតអាហារូបករណ៍ចៃកា

កញ្ញា ឃុន វត្តីស្រីល័ក្ខគឺជានិស្សិតអាហារូបករណ៍ក្រោមកម្មវិធី " លើកកម្ពស់ការវិនិយោគ និងការអភិវឌ្ឍន៍ឧស្សាហកម្មសម្រាប់តំបន់អាស៊ី" ។ គាត់បានសិក្សាថ្នាក់អនុបណ្ឌិតនៅមហាវិទ្យាល័យគ្រប់គ្រង និងសាកលវិទ្យាល័យ Ritsumeikan Asia Pacific (APU) ពីខែតុលា ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ។ វាជាពេលវេលាមួយដែលពិភពលោកកំពុងជួបប្រទះជម្ងឺរាតត្បាតកូវីត១៩ ហើយវាធ្វើឲ្យមានការលំបាកសម្រាប់និស្សិតបរទេសធ្វើដំណើរទៅសិក្សានៅប្រទេសជប៉ុន។ ឆ្លងកាត់ពេលវេលាដ៏លំបាកបែបនេះ កញ្ញាស្រីល័ក្ខណ៍បានតស៊ូព្យាយាមសិក្សាស្រាវជ្រាវ និងទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទថ្នាក់អនុបណ្ឌិតក្រោមប្រធានបទ " ការរក្សាបុគ្គលិកក្នុងវិស័យសាធារណៈ និងឯកជននៅប្រទេសកម្ពុជា៖ ការសិក្សាអំពី អ្នកផ្តល់សេវាអប់រំផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស "

ក្រៅពីរៀនជំនាញឯកទេសនៅសាកលវិទ្យាល័យនៅជប៉ុន កញ្ញាស្រីល័ក្ខណ៍ក៏ទទួលបានជំនាញក្នុងការទំនាក់ទំនង និងបានធ្វើឲ្យគាត់មានគំនិតទូលំទូលាយជាងមុន ចំពោះនិស្សិតដែលមានវប្បធម៌ផ្សេងៗគ្នា និងពីសាស្ត្រាចារ្យទាំងអស់របស់គាត់។

បន្ទាប់ពីបានត្រឡប់មកកាន់មាតុភូមិកម្ពុជាវិញ កញ្ញាស្រីល័ក្ខណ៍បានផ្តាំផ្ញើសារថា " នៅពេលដែលយើងដើរចេញពីទីកន្លែងធ្លាប់នៅសុខស្រួល វាជារឿងមិនងាយស្រួលនោះទេ ប៉ុន្តែសូមមានភាពក្លាហានក្នុងការធ្វើវា ព្រោះវាអាចឲ្យយើងរកឃើញនូវអ្វីដែលថ្មីដើម្បីអភិវឌ្ឍសមត្ថភាពរបស់យើង។ ជំហានដំបូងយើងប្រាកដជាប្រឈមនឹងរឿងជាច្រើន ប៉ុន្តែវាអាចផ្តល់ឲ្យយើងនូវឱកាស និងគំនិតថ្មីៗសម្រាប់អនាគតដ៏វែងឆ្ងាយ។៕●

ផ្នែកអភិវឌ្ឍន៍សង្គម និងអភិបាលកិច្ច

## JICA IN THE MEDIA

*"ក្រសួងសង្គមកិច្ច និង JICA កំពុងអនុវត្តគម្រោងរួមគ្នាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស"*

https://www.postkhmer.com/national/2023-11-08-0724-255840.html

ភ្នំពេញប៉ុស្តិ៍
០៨ វិច្ឆិកា ២០២៣

*"ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ជើងឯក នឹងលើកកម្ពស់គុណភាពទឹក និងអនាម័យ"*

*ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ជើងឯក នឹងលើកកម្ពស់គុណភាពទឹក និងអនាម័យ* – Khmer Times (khmertimeskh.com)

ខ្មែរថាមស៍

២៨ ធ្នូ ២០២៣

*"ជប៉ុនជួយជ្រោមជ្រែងកម្ពុជា ឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព"*

*ជប៉ុនជួយជ្រោមជ្រែងកម្ពុជា ឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព* - Khmer Times (khmertimeskh.com)

ខ្មែរថាមស៍

១៥ មករា ២០២៤

ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

ព័ត៌មានស្តីពីគម្រោង

វិច្ឆិកា ២០២៣ - កុម្ភៈ ២០២៤ ភាគ២ • ភ្នំពេញ



# គម្រោងធ្វើឲ្យប្រសើរឡើងផ្លូវជាតិលេខ៥

## ជួយជំរុញសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មបន្ថែម



ពិធីសម្ពោធផ្លូវជាតិលេខ៥

ផ្លូវជាតិលេខ៥ ត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជាផ្លូវអាស៊ានហាយវ៉េលេខ១ និងជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចភាគខាងត្បូង តភ្ជាប់ទីក្រុងភ្នំពេញ និងព្រះរាជាណាចក្រថៃ។ ផ្លូវជាតិលេខ៥បានកំពុងដើរតួនាទីយ៉ាងសំខាន់ និងកាន់តែខ្លាំងទាំងវិស័យដឹកជញ្ជូន និងភស្តុភារកម្ម

គម្រោងធ្វើឲ្យប្រសើរឡើងវិញផ្លូវជាតិលេខ៥ បានចាប់ផ្តើមការសិក្សាឡើងវិញនៅឆ្នាំ២០១៣ ដោយមានប្រវែងសរុប ៣៦៦គីឡូម៉ែត្រពីចំណុច ព្រែកក្តាម ដល់ប៉ោយប៉ែត ដែលបែងចែកជា៣ផ្នែកធំៗ គឺផ្នែកខាងជើង ខាងត្បូង និងកណ្តាល ។ ការសាងសង់រួមមានការពង្រីកផ្លូវជាតិ ដែលមានស្រាប់ពី ២គន្លង ទៅ៤គន្លងគ្របដណ្តប់ប្រវែង ៣០៤គីឡូម៉ែត្រ ដោយមានទទឹងប្រវែង២៣គីឡូម៉ែត្រជំនួសដោយកៅស៊ូ AC ។បន្ថែមពីនេះទៀត គម្រោង នេះក៏មានការសាសង់ស្ពានជំនួសស្ពាន ចាស់ និងស្ពានថ្មីចំនួន៨០កន្លែង។

ផ្នែកខាងជើងចាប់ពីបាត់ដំបង ដល់សិរិសោភ័ណ្ឌដែលមានប្រវែងជាង ៨៤.៧៤គីឡូម៉ែត្របានសម្រេចបញ្ចប់ការសាងសង់ទាំងស្រុងក្នុង ខែតុលា ឆ្នាំ២០២១ ។ ដោយឡែកផ្នែកខាងត្បូង និងកណ្តាលដែលមានប្រវែងសរុប ២៤៦.១៥ គីឡូម៉ែត្រចាប់ពីព្រែកក្តាមទៅបាត់ដំបង បានចាប់ផ្តើមបើកការដ្ឋានសាងសង់ជាផ្លូវការនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ ។ ពីធីសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការផ្នែកខាងត្បូង និងកណ្តាល ត្រូវបានធ្វើឡើងនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមវត្តមានសម្តេចបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោក UENO Atsushi ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក SANUI Kazumasa ប្រធានតំណាងការិយាល័យចៃកា ប្រចាំរាជាណាចក្រកម្ពុជា ក្នុងពិធីនោះដែរ សម្តេចបវរធិបតី ហ៊ុន ម៉ាណែតបានមានប្រសាសន៍ថា គម្រោងនេះនឹងពង្រឹងការតភ្ជាប់ក្នុងតំបន់ ក៏ដូចជាជំរុញសកម្មភាពសេដ្ឋកិច្ចសហគមន៍ក្នុងមូលដ្ឋានផងដែរ។

ចៃកាបានកំពុងអនុវត្តកិច្ចសហប្រតិបត្តិការបច្ចេកទេស លើគម្រោងធ្វើឲ្យប្រសើរឡើងវិញនូវសុវត្ថិភាពចរាចរណ៍ផ្លូវគោកលើផ្លូវសំខាន់ៗក្នុងព្រះរាជយាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០២១ រួមជាមួយនឹងគម្រោងផ្លូវជាតិលេខ៥។ គម្រោងនេះមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពចរាចរណ៍ និងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដោយផ្តោតលើចំនុចសំខាន់ៗ ៣ គឺពង្រឹងច្បាប់ ការអប់រំ និងវិស្វកកម្ម ។

លើសពី នេះគម្រោងគម្រោងកែលម្អការតភ្ជាប់ផ្លូវជនបទ ដែលស្ថិតក្រោមហិរញ្ញប្បអទានសម្បទានរបស់រដ្ឋាភិបាលជប៉ុនបានចុះហត្ថលេខានៅខែមិថុនា ឆ្នាំ២០២៣ ក្រោមការកែលម្អផ្លូវជនបទ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធលូក្នុងខេត្តតាមបណ្តោយផ្លូវជាតិលេខ៥។ គម្រោងនេះត្រូវបានគេរំពឹងថា នឹងផ្តល់អត្ថប្រយោជន៍បន្ថែមទៀតដល់ប្រជាពលរដ្ឋតាមខេត្ត បណ្តោយផ្លូវជាតិលេខ៥

គម្រោងនេះ បាននាំមកនូវអត្ថប្រយោជន៍ជាក់ស្តែងដល់ ប្រជាពលរដ្ឋរួមទាំងការពង្រឹងសុវត្ថិភាពចរាចរធ្វើឲ្យមានភាពងាយស្រួលក្នុងការដំណើរ ការសម្រួលដល់ការដឹកជញ្ជូនទំនិញពីកសិដ្ឋាន ទៅកាន់ ទីផ្សារ និងបង្កើនការទាក់ទាញសម្រាប់ភ្ញៀវទេសចរដែលមកទស្សនាខេត្តសំខាន់ៗ តាមដងផ្លូវនេះ។គម្រោងនេះក៏បានរួមចំណែកជួយជំរុញកំណើនសេដ្ឋកិច្ចតាមរយៈ ការជំរុញពាណិជ្ជកម្មជាមួយប្រទេសជិតខាង និងពង្រឹងការតភ្ជាប់ក្នុងតំបន់។

ពិតណាស់ប្រទេសកម្ពុជាតែងតែជួបប្រទះនឹងគ្រោះទឹកជំនន់ដោយផ្ទះសម្បែង សាលារៀន ដីកសិកម្ម និងផ្លូវថ្នល់ត្រូវបានជនលិច។ សមិទ្ធផលមួយនេះផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ ធ្វើដំណើរបានដោយមិនខ្វល់ខ្វាយ ពីការរាំងស្ទះក្នុងរដូវធ្លាក់ភ្លៀងខ្លាំង និងរដូវទឹកជំនន់។



គម្រោងធ្វើឲ្យប្រសើរឡើងវិញផ្លូវជាតិលេខ៥

ទោះបីជាគម្រោងបានប្រឈមមុខនឹងបញ្ហាជាច្រើនក៏ដោយ ការខិតខំប្រឹងប្រែងរួមគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់បានធ្វើឲ្យគម្រោងនេះ បញ្ចប់បានដោយជោគជ័យនៃគម្រោងនេះបញ្ជាក់ពីការប្តេជ្ញាចិត្តចំពោះវឌ្ឍនភាព មាគារអនាគតដ៏ភ្លឺស្វាង និងវិបុលសុខរបស់ប្រទេសកម្ពុជា៕•

ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម

# ពិធីចុះហត្ថលេខាលើកកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងជាមួយព្រះរាជាណាចក្រកម្ពុជា

## ដើម្បីរួមចំណែកដល់ការវាស់វែងយ៉ាងរហ័ស និងសុក្រិត តាមរយៈការអភិវឌ្ឍន៍បណ្តាញស្ថានីយវាស់វែងអចិន្ត្រៃយ៍

នៅថ្ងៃទី៦ ខែវិច្ឆិកា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តលជំនួយជាមួយរាជរដ្ឋាភិបាលកម្ពុជានៅទីក្រុងភ្នំពេញ ដើម្បីផ្តល់នូវហិរញ្ញប្បទានឥតសំណងដែលមានទឹកប្រាក់ រហូតដល់ មួយពាន់បីរយសាមសិបប្រាំបីលានយ៉េនជប៉ុន សម្រាប់គម្រោង បង្កើតបណ្តាញស្ថានីយវាស់វែងអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា ។




ពិធីចុះហត្ថលេខា (រូបថត៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

គោលបំណងនៃគម្រោងនេះ គឺដើម្បីលើកកម្ពស់គម្រោងអភិវឌ្ឍន៍ដទៃទៀតក្នុងប្រទេសកម្ពុជា តាមរយៈការពង្រឹងសេវាកម្មរដ្ឋបាល សម្រាប់ការចុះបញ្ជីដីធ្លី និងប្រតិបត្តិការដីធ្លីនៅកម្ពុជា។

គម្រោងនេះ នឹងធ្វើតាមរយៈការបង្កើតបណ្តាញស្ថានីយវាស់វែងអចិន្ត្រៃយ៍ និងមជ្ឈមណ្ឌលទិន្នន័យនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ តាមរយៈ គម្រោងសហប្រតិបត្តិការបច្ចេកទេសដែលកំពុងដំណើរការ ការអភិវឌ្ឍន៍សម្រាប់ការគ្រប់គ្រង់ដីធ្លី និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (២០២១-២០២៣) ចែកាកំពុងបង្កើតបណ្តាញ (CORS) និងមជ្ឈមណ្ឌលទិន្នន័យក្រុងភ្នំពេញ ខេត្តសៀមរាប និងខេត្តស្ទឹងត្រែងដើម្បីបង្កើនប្រតិបត្តិការ និងថែទាំមជ្ឈមណ្ឌលទិន្នន័យ និងដើម្បីលើកកម្ពស់ការប្រើប្រាស់ព័ត៌មានដែលមានមុខងារច្បាស់លាស់តាមរយៈបង្កើតប្រព័ន្ធ( CORS ) នៅក្នុងប្រទេសកម្ពុជាគម្រោងថ្មីនេះនឹងរួមចំណែកដល់ការពង្រីកលទ្ធផល នៃគម្រោងសហប្រតិបត្តិការផ្សេងទៀតនៅទូទាំងប្រទេស។

គម្រោងនេះបាននឹងកំពុងផ្តល់ ការកែលម្អបរិយាកាសរស់នៅក្នុងទីក្រុង ក៏ដូចជារួមចំណែកលើកកម្ពស់គុណភាពជីវិតរស់នៅប្រទេសកម្ពុជាដូចជាការសម្រេចបាននូវគោលដៅទី៩របស់ SDGs (ឧស្សាហកម្ម ការច្នៃប្រឌិត និងហេដ្ឋារចនាសម្ព័ន្ធ) និងគោលដៅទី១១ (ទីក្រុងសហគមន៍ប្រកបដោយចីរភាព)៕ ● ផ្នែកទំនាក់ទំនងសាធារណៈ

ព័ត៌មានលម្អិតសូមចុចលើតំណរភ្ជាប់ខាងក្រោម៖
https://www.jica.go.jp/english/information/press/2023/20231025_11.html

# អត្ថបទពិសេស អាស៊ាន-ជប៉ុន ចេញផ្សាយលើកទីកទី៣

## បញ្ហាប្រឈមនៃការតភ្ជាប់ដែលបានបង្ហាញពីច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង

នេះជាលើកទី៣ហើយ ក្នុងអត្ថបទពិសេសមួយនេះ ដើម្បីរំលឹកដ៏ខួបលើកទី៥០ នៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន។ អត្ថបទនេះ គឺចង់ឆ្លុះបញ្ចាំងពីការកសាងទំនុកចិត្ត និងទំនាក់ទំនងក្នុងការអភិវឌ្ឍន៍រវាងប្រទេសជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនជាមួយប្រទេសអាស៊ាន និងដៃគូរនាពេលអនាគត។

នៅខែតុលានេះ បុគ្គលិករបស់អង្គការ JICA និងអ្នកជំនាញពាក់ព័ន្ធបានធ្វើដំណើរតាមច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូង ប្រវែង ៩០០គីឡូម៉ែត្រពីទីក្រុងហូជីមិញប្រទេសវៀតណាម កាត់តាមទីក្រុងភ្នំពេញ ប្រទេសកម្ពុជាទៅកាន់ទីក្រុងបាងកក ប្រទេសថៃ។ ស្វែងយល់ពីស្ថានភាពបច្ចុប្បន្ននៃការតភ្ជាប់ និងបញ្ហាប្រឈម ដែលត្រូវតែដោះស្រាយដើម្បីពង្រឹងវា៕● ផ្នែកទំនាក់ទំនងសាធារណៈ



មន្ត្រីច្រកទ្វារព្រំដែនស្ទឹងបត់ថ្មី កម្ពុជា និងថៃ

https://www.jica.go.jp/english/information/topics/2023/20231211_01.html

## ទំនាក់ទំនងយើង

**ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា** គឺជាព្រឹត្តិប័ត្រប្រចាំឆមាស ដែលផ្តោតលើទស្សនវិស័យអន្តរជាតិរបស់ JICA និងការរួមចំណែករបស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក។ ព្រឹត្តិប័ត្រព័ត៌មាននេះរៀបរាប់អំពីការងាររបស់ JICA ក្នុងប្រទេសកម្ពុជា។

**ការិយាល័យចែកាប្រចាំនៅកម្ពុជា**
ជាន់ទី ១៦&១៧, អាគារ Keystone, #១៤៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +855-(0) 23-238 050
អ៊ីម៉ែល៖ cm_oss_rep@jica.go.jp

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) គឺជាទីភ្នាក់ងារជំនួយទ្វេភាគីធំជាងគេបំផុតនៅលើពិភពលោកដែលផ្តល់នូវជំនួយផ្សេងគ្នាជាច្រើនទម្រង់នៅប្រទេសជាង ១៥០ ជុំវិញពិភពលោក។

ស្វែងរកយើងខ្ញុំនៅទីនេះ!
គេហទំព័រ ហ្វេសប៊ុក